**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 40 PR-23/EoJ 14 November 2023

## Japan Provides US$424,907 for Irrigation Facility Rehabilitation and Construction of Bridges

The Government of Japan will provide US$424,907 in total for three recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between Mr. TANINAI Ichitomo, Chargés d'Affaires ad interim, Embassy of Japan in the Kingdom of Cambodia, and the representatives of three recipients respectively, to carry out the following projects.

1. 'The Project for Rehabilitation of Thnorldach Irrigation Facilities in Oddar Meanchey Province' (US$119,424)
Recipient: Oddar Meanchey Provincial Department of Water Resources and Meteorology
This grant will be used to rehabilitate the existing irrigation facilities with declined reservoir functions. This area is drought-prone during the dry season because the facilities cannot store an adequate amount of water during the rainy season. Moreover, due to the insufficient water storage capacity, this area is often affected by floods. The road connecting the facilities to the resident area is in poor condition and puts an heavy burden on farmers. It is expected to benefit over 1,000 local residents by ameliorating the irrigation facilities so that agricultural water will be secured and supplied in a stable manner throughout the year. In addition, improvement of residents' standard of living and incomes is anticipated as a result of an increased amount of rice produced in this area.

2. 'The Project for Construction of Bridge in Kampong Leaeng District, Kampong Chhnang Province' (US$137,207)
Recipient: Kampong Chhnang Provincial Department of Public Works and Transport
This grant will be used to replace the existing deteriorated bridge with a new concrete bridge. Despite the increasing number of local residents commuting to school and work every day, the old bridge has several holes and wires sticking out which threaten the safety of users. Furthermore, cars and emergency vehicles are not allowed to cross the bridge because it may

not be able to bear the weight and can collapse. It is expected to benefit about 10,000 local residents by allowing safe daily commutes. In addition, by enabling transportation of agricultural products, the increase in local population's incomes is anticipated.

3. 'The Project for the Construction of a Bridge in Ou Mras Commune, Siem Bouk District, Stung Treng Province' (US$168,276)
Recipient: Stung Treng Provincial Department of Rural Development
This grant will be used to replace the existing fragile wooden bridge with a new concrete bridge. While many local residents regularly cross the bridge to go to school, work and hospital as well as to carry agricultural products, the bridge is damaged and unsafe especially for children and the elderly. Moreover, because the number of heavy vehicles is expected to increase, existing bridge may not be able to endure and consequently it may collapse. It is expected to benefit around 2,800 residents in 4 villages by securing a safe path to the nearest school, market and health center throughout the year. The construction of a new bridge will also facilitate transportation of agricultural products, and therefore improved standard of living of the residents and increased agricultural incomes are anticipated.

Japan's *"KUSANONE" Projects* started in Cambodia in 1991 in order to support Cambodia's reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$68 million for mainly local authorities and non-governmental organizations to implement 684 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 40 PR-23/EoJ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

# ជប៉ុនផ្តល់ថវិកា ៤២៤,៩០៧ ដុល្លារអាមេរិក សម្រាប់ការស្តារប្រព័ន្ធធារាសាស្ត្រ និងការសាងសង់ស្ពាន

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ៤២៤,៩០៧ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនបី ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ) ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ លោក តានិណៃ អ៊ិឈិតុម៉ុ ភារធារីស្តីទីនៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយទាំងបី ដើម្បីអនុវត្តគម្រោងដូចតទៅ៖

## ១. គម្រោងស្តារប្រព័ន្ធធារាសាស្ត្រថ្នល់ដាច់ក្នុងខេត្តឧត្តរមានជ័យ (ថវិកាចំនួន ១១៩,៤២៤ ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយម ខេត្តឧត្តរមានជ័យ

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីស្តារប្រព័ន្ធធារាសាស្ត្រមានស្រាប់ដែលមានមុខងារអាងស្តុកទឹកអន់ថយ។ តំបន់នេះងាយរងគ្រោះរាំងស្ងួតក្នុងរដូវប្រាំង ដោយសារប្រព័ន្ធធារាសាស្ត្រមិនអាចស្តុកទឹកបានគ្រប់គ្រាន់ក្នុងរដូវវស្សា។ មិនតែប៉ុណ្ណោះ ដោយសារសមត្ថភាពស្តុកទឹកមិនគ្រប់គ្រាន់ តំបន់នេះជារឿយៗរងផលប៉ះពាល់ដោយទឹកជំនន់។ ផ្លូវតភ្ជាប់ពីប្រព័ន្ធធារាសាស្ត្រនេះទៅតំបន់ដែលប្រជាជនរស់នៅ មានស្ថានភាពយ៉ាប់យ៉ឺន ដែលដាក់បន្ទុកយ៉ាងធ្ងន់ដល់កសិករ។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមូលដ្ឋានប្រមាណ ១,០០០ នាក់ តាមរយៈការកែលម្អប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្មប្រកបដោយស្ថិរភាពពេញមួយឆ្នាំ។ លើសពីនេះ យើងរំពឹងថាកម្រិតជីវភាពរស់នៅ និងប្រាក់ចំណូលរបស់ប្រជាជននឹងមានភាពប្រសើរឡើង ដោយសារមានការកើនឡើងនៃបរិមាណស្រូវដែលផលិតបាននៅក្នុងតំបន់នេះ។

## ២. គម្រោងសាងសង់ស្ពានក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង (ថវិកាចំនួន ១៣៧,២០៧ ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយ ជំនួសឱ្យស្ពានបច្ចុប្បន្នដែលមានសភាពទ្រុឌទ្រោម។ ទោះបីមានការកើនឡើងនៃចំនួនប្រជាជនដែលធ្វើដំណើរទៅសាលារៀន និងកន្លែងធ្វើការជារៀងរាល់ថ្ងៃ ស្ពានចាស់នេះមានកន្លែងធ្លុះធ្លាយ ចេញដែកមកខាងក្រៅ ដែលគំរាមកំហែងដល់សុវត្ថិភាពអ្នកធ្វើដំណើរ។ លើសពីនេះ ឡាននិងរថយន្តសង្គ្រោះបន្ទាន់មិនត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់ស្ពាននេះទេ ព្រោះស្ពាន

នេះមិនអាចទ្រទ្រង់បាន និងអាចរងការបាក់ស្រុត។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមូលដ្ឋានប្រមាណ ១០,០០០ នាក់ តាមរយៈការផ្តល់លទ្ធភាពក្នុងការធ្វើដំណើរប្រចាំថ្ងៃប្រកបដោយសុវត្ថិភាព។ មិនតែប៉ុណ្ណោះ យើងរំពឹងថា តាមរយៈការផ្តល់លទ្ធភាពក្នុងការដឹកជញ្ជូនកសិផល ប្រាក់ចំណូលរបស់ប្រជាជននឹងមានការកើនឡើង។

**៣. គម្រោងសាងសង់ស្ពានក្នុងឃុំអូរម្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង (ថវិកាចំនួន ១៦៨,២៧៦ ដុល្លារអាមេរិក)**

*ស្ថាប័នទទួលជំនួយ៖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង*

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីសង់ស្ពានបេតុងថ្មីមួយ ជំនួសឱ្យស្ពានឈើពុកផុយបច្ចុប្បន្ន។ ខណៈដែលប្រជាជនមូលដ្ឋានជាច្រើនតែងតែឆ្លងកាត់ស្ពាននេះដើម្បីទៅសាលារៀន កន្លែងធ្វើការ និងមន្ទីរពេទ្យ ព្រមទាំងដឹកជញ្ជូនកសិផល ស្ពាននេះបានរងការខូចខាត និងគ្មានសុវត្ថិភាព ជាពិសេសសម្រាប់កុមារ និងមនុស្សចាស់។ បន្ថែមពីនេះ ដោយសារចំនួនរថយន្តធុនធ្ងន់ត្រូវបានរំពឹងថានឹងមានការកើនឡើង ស្ពានបច្ចុប្បន្ននេះប្រហែលមិនអាចទ្រាំទ្របានទេ ហើយជាលទ្ធផលអាចនឹងមានការបាក់ស្រុត។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ២,៨០០ នាក់ ក្នុងភូមិចំនួន ៤ តាមរយៈការធានាបាននូវផ្លូវធ្វើដំណើរប្រកបដោយសុវត្ថិភាពទៅសាលារៀន ផ្សារ និងមណ្ឌលសុខភាពដែលនៅជិតបំផុតពេញមួយឆ្នាំ។ ការសាងសង់ស្ពានថ្មីក៏នឹងជួយសម្រួលដល់ការដឹកជញ្ជូនកសិផលផងដែរ ដែលយើងរំពឹងថានឹងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងបង្កើនប្រាក់ចំណូលកសិកម្ម។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្ថាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៦៨លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិ ចំនួន ៦៨៤ គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១*

*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*

*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **លោក តានិណៃ អ៊ិឈិតុម៉ុ**
ភារធារីស្ដីទីនៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយឥតសំណង
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

សូមគោរព
- **លោក ញឹន កួន** ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តឧត្តរមានជ័យ
- **លោក ឆាយ លាភា** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង
- **លោក ព្រំ ចាន់ថា** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយឥតសំណង សម្រាប់គម្រោងគូសាណូណិ ឬគម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ បន្ថែមលើគម្រោងឥណទាននិងជំនួយឥតសំណងខ្នាតធំ រដ្ឋាភិបាលជប៉ុន បាននិងកំពុងអនុវត្តគម្រោងគូសាណូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឬសស្មៅ" ក្នុងភាសាជប៉ុន។ នៅក្នុងរយៈពេលជាង៣០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុន បានចូលរួមចំណែកក្នុងគម្រោងជាង ៦៨៤ នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍នេះ។ យើងមានសេចក្ដីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ថ្ងៃនេះ ខ្ញុំសូមណែនាំគម្រោងចំនួនបីដែលបានចុះហត្ថលេខា ដូចខាងក្រោម៖

សម្រាប់គម្រោងទី១ សម្រាប់មន្ទីរធនធានទឹក និងឧតុនិយមខេត្តឧត្តរមានជ័យ រដ្ឋាភិបាលជប៉ុនផ្ដល់ថវិកាចំនួន ១១៩,៤២៤ ដុល្លារអាមេរិក (មួយរយដប់ប្រាំបួនពាន់បួនរយម្ភៃបួនដុល្លារអាមេរិក) ដើម្បីស្ដារប្រព័ន្ធធារាសាស្ត្រក្នុងខេត្តឧត្តរមានជ័យ។ បរិក្ខារទាំងនេះនឹងរួមចំណែកធានាបាននូវការផ្គត់ផ្គង់ទឹកសម្រាប់កសិកម្ម ព្រមទាំងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងបង្កើនប្រាក់ចំណូលរបស់កសិករផងដែរ។

សម្រាប់គម្រោងទី២ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង រដ្ឋាភិបាលជប៉ុនផ្ដល់ថវិកាចំនួន ១៣៧,២០៧ ដុល្លារអាមេរិក (មួយរយសាមសិបប្រាំពីរពាន់ពីររយប្រាំពីរដុល្លារអាមេរិក) ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយ ជំនួសឱ្យស្ពានបច្ចុប្បន្នដែលមានសភាពទ្រុឌទ្រោម ក្នុងខេត្តកំពង់ឆ្នាំង។ យើងរំពឹង

ថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនមូលដ្ឋានប្រមាណ ១០,០០០ នាក់ តាមរយៈការផ្តល់លទ្ធភាពក្នុងការធ្វើដំណើរប្រកបដោយសុវត្ថិភាព និងការដឹកជញ្ជូនកសិផលបានពេញមួយឆ្នាំ។

សម្រាប់គម្រោងទី៣ សម្រាប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៦៨,២៧៦ ដុល្លារអាមេរិក (មួយរយហុកសិបប្រាំបីពាន់ពីររយចិតសិបប្រាំមួយដុល្លារអាមេរិក) ដើម្បីសាងសង់ស្ពានបេតុងថ្មីមួយក្នុងខេត្តស្ទឹងត្រែង។ ស្ពាននេះនឹងរួមចំណែកសម្រួលដល់ការដឹកជញ្ជូនកសិផល និងធានាបាននូវផ្លូវធ្វើដំណើរប្រកបដោយសុវត្ថិភាព ទៅសាលារៀន ផ្សារ និងមណ្ឌលសុខភាពដែលនៅជិតបំផុត។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជា បាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិត។ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ផ្សេងៗ រួមទាំង "គូសាណូណេ" ផងដែរ។

សូមអរគុណសម្រាប់ការចូលរួមក្នុងពិធីចុះហត្ថលេខានាថ្ងៃនេះ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ៕